ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......សហវ.

# ប្រកាស

## ស្តីពី

## យន្តការបង្វិលសងអាករលើតម្លៃបន្ថែម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងរៀបចំយន្តការបង្វិលសងអាករលើតម្លៃបន្ថែមឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីធានាបាននូវការជឿទុកចិត្តពីអ្នកជាប់ពន្ធក្នុងការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែម។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នូវលក្ខខណ្ឌនិងលក្ខណសម្បត្តិនៃការស្នើសុំបង្វិលសង និងវិធានការងារ បង្វិលសងអាករលើតម្លៃបន្ថែមដើម្បីឱ្យការស្នើសុំបង្វិលសងបានឆាប់រហ័សស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការស្នើសុំបង្វិលសងរបស់សហគ្រាសទាំងឡាយ ដែលបានចុះបញ្ជីពន្ធដារ ហើយមានផលរបរចាប់ពីកម្រិតអ្នកជាប់ពន្ធមធ្យមឡើងទៅ និងបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

**ប្រការ ៤.- លក្ខខណ្ឌនៃការស្នើសុំបង្វិលសង**

១. យោងតាមមាត្រា៧២ និងមាត្រា៧៣ នៃច្បាប់ស្តីពីសារពើពន្ធ មាត្រា៤០ និងមាត្រា៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម អ្នកជាប់ពន្ធដែលមានសិទ្ធិស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម÷

ក. មានឥណទានអាករលើធាតុចូលលើសប្រចាំខែ ចំពោះបុគ្គលជាប់អាករដែលមានការនាំចេញជាសំខាន់ ឬបានចុះបញ្ជីជាសហគ្រាសវិនិយោគ

ខ. មានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ ខែ ជាប់គ្នា ឡើងទៅ ចំពោះបុគ្គលជាប់អាករដទៃទៀត

គ. មានភ័ស្តុតាងនៃការបង់ប្រាក់អាករលើធាតុចូល រួមមានប្រតិវេទន៍គយសម្រាប់ការនាំចូលព្រមទាំងច្បាប់ដើមនៃបង្កាន់ដៃគយដែលបញ្ជាក់ពីការបង់ប្រាក់អាករដែលអាចអនុញ្ញាតជាឥណទាន ឬច្បាប់ដើមនៃវិក្កយបត្រអាករចេញដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក

ឃ. មានភ័ស្តុតាងនៃការនាំចេញដែលត្រូវជាប់អាករតាមអត្រាសូន្យ

ង. មានបញ្ជីគណនេយ្យអាករលើតម្លៃបន្ថែមដែលអាចជឿទុកចិត្តបាន រួមមាន ទិនានុប្បវត្តិទិញ-លក់ព្រមទាំងកំណត់ត្រាជំនួយផ្សេងៗ។

២. ចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការស្នើសុំបង្វិលសងត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម÷

ក. ចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន

ខ. ដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារតាមទម្រង់ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ

គ. វិក្កយបត្រទិញនីមួយៗត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអាករ ចាប់ពី ២០០ ០០០ រៀលឡើងទៅ

ឃ. ពាក្យស្នើសុំបង្វិលសងនីមួយៗត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអាករចាប់ពី ២ ០០០ ០០០ រៀលឡើងទៅ

ង. ពាក្យស្នើសុំត្រូវមានការបញ្ជាក់ពីប្រធានបេសកកម្ម ជូនអគ្គនាយកដ្ឋានពន្ធដារថា ទំនិញត្រូវបានទិញសម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់បេសកកម្មពិតប្រាកដមែន។

## ប្រការ ៥.- វិធានការទារបង្វិលសងអាករលើតម្លៃបន្ថែម

១. សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ចំពោះក្រុមហ៊ុន ត្រូវអនុវត្តដូចខាងក្រោម÷

- អ្នកជាប់ពន្ធត្រូវបំពេញនិងដាក់លិខិតប្រកាសនិងស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម តាមទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនត្រឡប់ទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ
- បន្ទាប់ពីបានកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធត្រូវរៀបចំឯកសារដើម្បីធ្វើសវនកម្មផ្ទៀងផ្ទាត់ និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច
- ក្នុងករណីអ្នកជាប់ពន្ធទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស អគ្គនាយកដ្ឋានពន្ធដារអាចពិនិត្យសម្រេចអនុញ្ញាតផ្តល់ជូនតែម្តងដោយពុំចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន ឬធ្វើសវនកម្មតាមក្រោយក្នុងករណីចាំបាច់
- ក្រោយពីទទួលបានការសម្រេចរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ
- បន្ទាប់មក នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារត្រូវបញ្ជូនលិខិតជូនដំណឹងស្តីពីការផ្តល់ជូនប្រាក់ស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ។

២. សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានាត្រូវអនុវត្តដូចខាងក្រោម÷

- បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានាត្រូវដាក់លិខិតស្នើសុំដោយផ្ទាល់មកនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ
- បន្ទាប់ពីបានកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធត្រូវពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារស្នើសុំបង្វិលសង និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច
- ក្រោយពីទទួលបានការសម្រេចរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និង

កត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ

- នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលិខិតជូនដំណឹងស្តីពីការផ្តល់ជូនប្រាក់ស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ។

តារាងវិហ្វូរការងារបង្វិលសងអាករលើតម្លៃបន្ថែម មានភ្ជាប់ជាឧបសម្ព័ន្ធ ជាមួយនឹងប្រកាសនេះ។

**ប្រការ ៦.- កាតព្វកិច្ចរបស់អ្នកស្នើសុំបង្វិលសង**

ដើម្បីធានាឱ្យការបង្វិលសងប្រព្រឹត្តទៅបានឆាប់រហ័ស អ្នកជាប់ពន្ធ ឬបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាត្រូវផ្តល់បញ្ជីគណនេយ្យនិងឯកសារនានា ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ឱ្យបានគ្រប់គ្រាន់និងតាមពេលវេលាកំណត់របស់អគ្គនាយកដ្ឋានពន្ធដារ ពុំនោះទេការស្នើសុំបង្វិលសងនឹងត្រូវបានព្យួរទុករហូតដល់ថ្ងៃដែលអគ្គនាយកដ្ឋានពន្ធដារបានទទួលបញ្ជីគណនេយ្យនិងឯកសារគ្រប់គ្រាន់។

**ប្រការ ៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ....................សហវ

# ឧបសម្ព័ន្ធទី១

## នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុន

ភ្ជាប់ជាមួយប្រកាសលេខ.៥៧៦....សហវ.ប្រក ចុះថ្ងៃទី.១៩.ខែ.មិថុនា.ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**អ្នកជាប់ពន្ធដាក់លិខិតប្រកាសនិងស្នើសុំ**

↓

| | | |
|---|---|---|
| ១ | **នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអពដ** | កត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបិទបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនត្រឡប់ទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ |
| ២ | **អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ នៃអពដ** | ទទួលលិខិតប្រកាសរបស់អ្នកជាប់ពន្ធដែលស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម តាមទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងត្រូវរៀបចំឯកសារដើម្បីធ្វើសវនកម្មផ្ទៀងផ្ទាត់ និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច ឬក្នុងករណីអ្នកជាប់ពន្ធទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស អគ្គនាយកដ្ឋានពន្ធដារអាច ពិនិត្យសម្រេចអនុញ្ញាតផ្តល់ជូនតែម្តងដោយពុំចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន ឬធ្វើសវនកម្មជាក្រោយក្នុងករណីចាំបាច់ |
| ៣ | **ថ្នាក់ដឹកនាំ នៃអពដ ពិនិត្យសម្រេច** | ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារ ពិនិត្យសម្រេច លើសំណុំឯកសារស្នើសុំ |
| ៤ | **នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអពដ** | - រៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ<br>- បញ្ជូនលិខិតជូនដំណឹងភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |
| ៥ | **អគ្គនាយកដ្ឋានរតនាគារជាតិ** | បង្វែរប្រាក់បង្វិលសងអាករលើតម្លៃបន្ថែមចូលទៅគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |

**កំណត់សម្គាល់÷**

ការបង្វិលសងអាករលើតម្លៃបន្ថែមចំពោះក្រុមហ៊ុននានានឹងប្រើប្រាស់រយៈពេលប្រហែល **៤០ ថ្ងៃ** នៃថ្ងៃធ្វើការ ឬឆាប់ជាងនេះសម្រាប់សហគ្រាសដែលទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ....................សហវ

# ឧបសម្ព័ន្ធទី២

## ស្តីពី

## នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា

ភ្ជាប់ជាមួយប្រកាសលេខ.............. សហវ.ប្រក ចុះថ្ងៃទី...... ខែ........... ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**បេសកកម្មទូត អង្គការអន្តរជាតិ...ដាក់លិខិតស្នើសុំ**

| | | |
|---|---|---|
| ១ | **នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអពដ** | កត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបិទបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ |
| ២ | **អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ នៃអពដ** | ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារស្នើសុំបង្វិលសង និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច |
| ៣ | **ថ្នាក់ដឹកនាំ នៃអពដ ពិនិត្យនិងសម្រេច** | ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំ |
| ៤ | **នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអពដ** | - រៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំ ឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ<br>- បញ្ជូនលិខិតជូនដំណឹងភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |
| ៥ | **អគ្គនាយកដ្ឋានរតនាគារជាតិ** | បង្វែរប្រាក់បង្វិលសងអាករលើតម្លៃបន្ថែមចូលទៅគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |

**កំណត់សម្គាល់÷**

ការបង្វិលសងអាករលើតម្លៃបន្ថែមចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា នឹងប្រើប្រាស់រយៈពេលប្រហែល **១៥ ថ្ងៃ** នៃថ្ងៃធ្វើការ។